ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៤០/១៤ - ផាំង ឈូ អ៊ែលឡឺធី ហ្គាមេន ហ្វេកធើរី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ផាំង ឈូ អ៊ែលឡឺធី ហ្គាមេន ហ្វេកធើរី**

អាសយដ្ឋាន ៖ ផ្លូវលេខ ២៨ គ្រួសារ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦០៦ ៨២៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- អ្នកស្រី ប៊ុន សុខហុង ប្រធានរដ្ឋបាល

២- លោក កែវ សុភក្តិ រដ្ឋបាលរង

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ**

- **សហជីពសម្លេងយុវជនខ្មែរប្រចាំក្រុមហ៊ុន ផាន់ហ្វ៊ូល លីធី ហ្គាមិន ខូ អិលធីឌី**

អាសយដ្ឋាន ៖ ផ្ទះលេខ ១៧ ភូមិដំណាក់ធំ២ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៧១៣ ០៦៥ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក អន សាខន អគ្គលេខាធិការសហព័ន្ធសហជីពសម្លេងយុវជនខ្មែរ

២- លោក ឡាយ ឆៃម៉ៅ មន្ត្រីសហព័ន្ធសហជីពសម្លេងយុវជនខ្មែរ

៣- លោក ភីម សុផាត ប្រធានសហជីពសម្លេងយុវជនខ្មែរ

៤- អ្នកស្រី ខ្វាន់ សុខលី អនុប្រធានសហជីពសម្លេងយុវជនខ្មែរ

៥- អ្នកស្រី អែម មួយគា លេខាធិការិនីសហជីពសម្លេងយុវជនខ្មែរ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនទទួលយកអនុប្រធានសហជីពសម្លេងយុវជនខ្មែរឈ្មោះអ្នកស្រី ខ្វាន់ សុខលី ចូលធ្វើការវិញ ព្រមទាំងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃទទួលយកចូលធ្វើការវិញ។

២- សុំឱ្យក្រុមហ៊ុនកុំយកកងកំលាំងប្រដាប់អាវុធ (យោធា) មកគំរាមកំហែងកម្មករនិយោជិត។

៣- នៅពេលធ្វើការបន្ថែមម៉ោង គឺផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។

៤- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានគ្រូពេទ្យប្រចាំការរៀងរាល់ម៉ោងការងាររបស់កម្មករនិយោជិត។

៥- នៅពេលកម្មករនិយោជិតធ្វើការលើសពី ២ ខែ ឡើងទៅ ត្រូវបញ្ចូលជាកម្មករពេញសិទ្ធិ។

៦- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យសុខភាពកន្លះថ្ងៃក្នុងមួយខែ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ផាន់ ហ្សូល លីធី លេខ ១៨៥ កប/អក/វក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០១៤។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងរបស់សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ ស្ដីពីសំណើសុំអន្តរាគមន៍ជួយដោះស្រាយ កែលម្អលក្ខខណ្ឌការងារមួយចំនួន។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា លើការទាមទារចំនួន ០៦ ចំណុច។ ចំណុចមិនសះជាចំនួន ០៦ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ១៨៥/១៤ ក.ប/អក/វក. ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើង នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើការកោះអញ្ជើញភាគីទាំងពីរ មកសវនាការ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ វេលាម៉ោង ២៖០០ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៦ ចំណុចនេះបន្ថែម ទៀត ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាលើចំណុចវិវាទចំនួន ០៥ ចំណុច គឺ៖ ចំណុចវិវាទទី២,ទី៣,ទី៤,ទី៥ និងទី៦។ ដូចនេះ ចំណុចវិវាទដែលនៅសល់ គឺចំណុចវិវាទទី១។

ក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច។

ភាគីនិយោជក និងភាគីកម្មករនិយោជិត បានឯកភាពពន្យារថ្ងៃចេញសេចក្ដីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ ទៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ របស់ប្រធានរោងចក្រ ផាន់ ហ្សួល លីធី ផ្ទេរសិទ្ធិជូនឈ្មោះ ប៊ុន សុខហុង និង កែវ សុភ័ក្ត្រ ។

២- សេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស ផាំង ឈូ អ៊ែឡិចធី ហ្គាមេន ហ្វេកធើរី ចុះបញ្ជិកាលេខ ២៤៨២ មកបវ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ ដោយប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានីភ្នំពេញ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ផាំង ឈូ អ៊ែឡិចធី ហ្គាមេន ហ្វេកធើរី បានឃើញ និងបញ្ជាក់ថា ត្រឹមត្រូវ

លេខ ២៧១៥ មកបវ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ។

៤- ព័ត៌មានកម្មករនិយោជិត(ប្រវត្តិផ្ទាល់ខ្លួន) របស់ឈ្មោះ ខ្វាន់ សុខលី ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ ។

៥- កិច្ចសន្យាការងាររបស់ឈ្មោះ ខ្វាន់ សុខលី ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ និងវិន័យ និងបទបញ្ជារបស់ក្រុមហ៊ុន ។

៦- សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ ខ្វាន់ សុខលី ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៥ ។

៧- ប័ណ្ណសំគាល់កម្មករនិយោជិតខ្មែរ លេខ ២៤២៥៨៧ សកបយ ។

៨- លិខិតផ្តាច់កិច្ចសន្យាការងាររបស់ឈ្មោះ ខ្វាន់ សុខលី ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ។

៩- លិខិតសំណូមពរពេលធ្វើការថ្ងៃបុណ្យ និងពេលថែមម៉ោងថ្ងៃអាទិត្យ ។

១០- លិខិតចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ របស់ឈ្មោះ ខ្វាន់ សុខលី ដើម្បីទទួលកំហុស និងទទួលការព្រមានពីក្រុមហ៊ុន ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតលេខ ២៦២/១៣ សសសយខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ របស់សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ គោរពជូន នាយកក្រុមហ៊ុន ផាន់ហ្សួលលីធី ហ្គាមិន ខូ អិលធីឌី ជូនដំណឹងស្តីពីការរៀបចំបង្កើតបង្កើតសហជីពសម្លេងយុវជនខ្មែរប្រចាំក្រុមហ៊ុន ។

២- បង្កាន់ដៃទទួលសំណុំរឿងរបស់នាយកដ្ឋានវិវាទការងារ ដែលបានទទួលពីសហជីពសម្លេងយុវជនខ្មែរ (ផាន់ស្យួល) សុំចុះបញ្ជិកាសហជីព ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ។

៣- លិខិតលេខ ០២៦/១៤ សសសយខ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ របស់សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ សុំជួយអន្តរាគមន៍ដោះស្រាយនូវករណីវិវាទការងារ របស់កម្មករនិយោជិតក្រុមហ៊ុន ផាន់ហ្សួលលីធី ។

៤- លិខិតចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ របស់កម្មករ កម្មការិនីបំរើការងារក្នុងក្រុមហ៊ុន ផាន់ហ្សួលលីធី គោរពចូលមក ប្រធានសហព័ន្ធសហជីពសម្លេងយុវជនខ្មែរ សំណើសុំជួយអន្តរាគមន៍ដោះស្រាយសំណូមពរលក្ខខណ្ឌការងារមួយចំនួន ។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ផាន់ ហ្សួល លីធី ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

៦- សាលាកប័ត្រផ្ញើសេវា EMS ដែលបានផ្ញើពីសហព័ន្ធសហជីពសម្លេងយុវជនខ្មែរ ទៅក្រុមហ៊ុន ផាន់ហ្សួលលីធី ហ្គាមិន ខូ អិលធីឌី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ផាន់ ហ្សួល លីធី លេខ ១៨៥ គប/អក

/វក ចុះ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ផាន់ ហ្សួល លីធី ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ២២៧ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ២២៨ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ផាំងឈូអ៊ែឡីធី ហ្គាមេនហ្វេកធើរី (PUNTUALITY GARMENT FACTORY Co.,Ltd.) (តទៅនេះ ហៅថា "ក្រុមហ៊ុន ផាំងឈូអ៊ែឡីធី") ជាភាគីនិយោជកនៅក្នុងសំណុំរឿងនេះ មានជួលកម្មករនិយោជិតចំនួនប្រហែល ១៩០ នាក់។
- សហជីពសម្លេងយុវជនខ្មែរទទួលបានបង្កាន់ដៃសុំចុះបញ្ជិកាសហជីពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣។ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបញ្ជាក់ថា ក្រោយរយៈពេលពីរខែបានផុត សហជីពបានទៅសួរក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អំពីការចុះបញ្ជិកាសហជីពរបស់ពួកគាត់ ហើយក្រសួងការបានឆ្លើយថា ក្រសួងមិនទាន់បានចេញបញ្ជិកាសហជីពទេ ។
- ភាគីទាំងពីរបញ្ជាក់ថា ក្នុងអំឡុងពេលពីរខែនេះ ពួកគាត់មិនទទួលបានលិខិតផ្លូវការណាមួយទាក់ទងនឹងការបដិសេធសមាសភាពថ្នាក់ដឹកនាំសហជីព ឬការចុះបញ្ជិកាសហជីពទេ។
- នៅថ្ងៃសវនាការ កម្មការិនី ខ្វាន់ សុខលី បានចូលរួមសវនាការ ហើយបានអះអាងថា គាត់ជាអនុប្រធានសហជីពសម្លេងយុវជនខ្មែរ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជក ទទួលយកអនុប្រធានសហជីពសម្លេងយុវជនខ្មែរឈ្មោះ អ្នកស្រី ខ្វាន់ សុខលី ចូលធ្វើការវិញ និងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ**

- ភាគីទាំងពីរទទួលស្គាល់ថា កម្មការិនី ខ្វាន់ សុខលី ចូលធ្វើការនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ ដោយមាន

កិច្ចសន្យាការងារសាកល្បងចំនួន ០៣ ខែ។ បន្ទាប់ពីចប់រយៈពេលសាកល្បង ចាប់ពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ កម្មការិនី ខ្វាន់ សុខលី បានបន្តធ្វើការដោយមិនមានកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរទេ។ និយោជកបានបញ្ឈប់ កម្មការិនី ខ្វាន់ សុខលី ពីការងារនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤។

- ភាគីកម្មករនិយោជិតបញ្ជាក់ពីមូលហេតុនៃការទាមទារថា ៖
  - កម្មការិនី ខ្វាន់ សុខលី មិនមានកំហុសឈានដល់ការបញ្ឈប់ពីការងារទេ
  - គាត់ជាថ្នាក់ដឹកនាំសហជីព ដូចនេះ និយោជកគោរពតាមនីតិវិធីច្បាប់ ក្នុងការបញ្ឈប់គាត់ពីការងារ។
- ភាគីនិយោជកបញ្ជាក់ថា ៖
  - កម្មការិនី ខ្វាន់ សុខលី បានអវត្តមានគ្មានច្បាប់ចំនួន ០៦ ថ្ងៃ គឺៈ នៅថ្ងៃទី០៣,ទី០៦,ទី០៨, ទី០៩,ទី១១ និងទី១៣ ខែមករា ឆ្នាំ២០១៤។
  - នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ពេលដែលកម្មការិនី ខ្វាន់ សុខលី ចូលធ្វើការវិញ និយោជក និងខាងរដ្ឋបាលបានសួរគាត់ថា ទៅណាបានជាមិនមកធ្វើការ។ ពេលនោះ គាត់បានឆ្លើយតបថា គាត់ឈប់ឈឺ។ ខាងរដ្ឋបាលបានតម្រូវឱ្យគាត់ដាក់សំបុត្រពេទ្យមកក្រុមហ៊ុន បើគាត់ឈប់ឈឺ។ ពេលនោះគាត់បានឆ្លើយតបថា អត់មានទេ ហើយឈប់ប៉ុណ្ណឹងត្រូវការសំបុត្រពេទ្យដែរ? រួចគាត់ក៏បាននិយាយគំរាមដល់និយោជកថា តើចង់ឱ្យទំនិញចេញទាន់ពេលអត់? ក្រោយមកគាត់បានផ្តល់វិក្កយបត្រទិញថ្នាំមកខាងរដ្ឋបាល។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ៖
  - នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ គាត់បានមកធ្វើការ
  - ពេលគាត់ឈប់សម្រាកបានប្រាប់ប្រធានក្រុម និងបានសុំច្បាប់ផ្ទាល់មាត់ទៅរដ្ឋបាល ពេលនោះរដ្ឋបាលបានឱ្យ ទៅសិនទៅ ចាំសរុបពេលត្រឡប់ចូលធ្វើការវិញ
  - ការឈប់សម្រាករបស់គាត់ គឺដោយសារ ទៅចូលរួមការបងប្អូន និងបញ្ហាសុខភាពផ្ទាល់ខ្លួន របស់គាត់ (ដោយសារគាត់បានលេបថ្នាំទម្លាក់កូន នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤)
  - នៅពេលចូលធ្វើការវិញ ខាងរដ្ឋបាលបានសួររកសំបុត្រពេទ្យ ពេលនោះ គាត់បានឆ្លើយថា គាត់អត់មានឈឺទេ ហើយក៏មិនមានសំបុត្រពេទ្យដែរ គឺមានតែវិក្កយទិញថ្នាំពេទ្យ។ គាត់មិនបាននិយាយគំរាមនិយោជកទេ ដោយសារពេលនោះ គឺមានអ្នកបកប្រែឱ្យនិយោជក ហើយគាត់មិនដឹងថា គេបកប្រែអ្វីខ្លះឱ្យនិយោជកទេ។
- ភាគីនិយោជកបញ្ជាក់ថា កម្មការិនី ខ្វាន់ សុខលី មិនបានមកសុំច្បាប់ពីគាត់ទេ។ ជាទូទៅ នៅពេលកម្មករនិយោជិតណាមួយមកសុំច្បាប់ គឺគាត់តែងតែអនុញ្ញាតច្បាប់ឱ្យ។
- ភាគីនិយោជកបញ្ជាក់ថា និយោជកមិនអាចទទួលយកគាត់ចូលធ្វើការវិញទេ ដោយមូលហេតុថា ៖
  - កម្មការិនី ខ្វាន់ សុខលី បានអវត្តមានអត់ច្បាប់

- បានប្រើពាក្យសម្ដីមិនសមរម្យ និងគំរាមដល់និយោជក

- ភាគីនិយោជកបន្តថា នៅពេលបញ្ឈប់ កម្មការិនី ខ្វាន់ សុខលី និយោជកមិនបានសុំការអនុញ្ញាតពីអធិការការទេ។

**ព័ត៌មានទាក់ទងនឹងសហជីព ៖**

- ភាគីកម្មករនិយោជិតបញ្ជាក់ថា ៖
  - នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ សហព័ន្ធសហជីពបានរៀបចំបង្កើតសហជីពសម្លេងយុវជនខ្មែរ
  - នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ សហព័ន្ធបានជូនដំណឹងទៅនិយោជកអំពីបេក្ខភាព ដែលមានការគាំទ្រជាថ្នាក់ដឹកនាំសហជីពមានដូចជា៖ ១. កម្មករ ភឹម សុផាត ជាប់ជាប្រធាន ២. កម្មការិនី ខ្វាន់ សុខលី ជាប់ជាអនុប្រធាន ៣. កម្មការិនី អែម មួយគា ជាប់ជាលេខាធិការិនី។
- ភាគីនិយោជកទទួលស្គាល់ថា បានឃើញលិខិតជូនដំណឹងស្ដីពីសមាសភាពថ្នាក់ដឹកនាំសហជីពសម្លេងយុវជនខ្មែរ ក្នុងអំឡុងខែតុលា។

**ហេតុផលនៃសេចក្ដីសម្រេច ÷**

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការបកស្រាយជាមុនសិនអំពីភាគីដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ។

កថាខណ្ឌទី២ នៃមាត្រា ២៦៨ នៃច្បាប់ស្ដីពីការងារចែងថា ៖ *"ក្នុងរយៈពេលពីរខែ ក្រោយពីបានទទួលសំណុំបែបបទសុំចុះបញ្ជិកា បើក្រសួងទទួលបន្ទុកវិស័យការងារមិនបានឆ្លើយតប ត្រូវចាត់ទុកអង្គការវិជ្ជាជីវៈនោះថាបានចុះបញ្ជិការួចហើយ ។"*

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ក្រោយរយៈពេលពីរខែបានផុត សហជីពបានទៅសួរក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ អំពីការចុះបញ្ជិកាសហជីពរបស់ពួកគាត់ ហើយក្រសួងការបានឆ្លើយថាមិនទាន់បានចេញបញ្ជិកាសហជីពទេ។ មកដល់ថ្ងៃសវនាការ ភាគីក៏បានឯកភាពថា ពួកគាត់មិនទទួលបានការជូនដំណឹងពីការបដិសេធរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លើការចុះបញ្ជិកាសហជីពនេះដែរ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា សហជីពសម្លេងយុវជនខ្មែរទទួលបានបង្កាន់ដៃសុំចុះបញ្ជិកាសហជីពពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣។ បើរាប់ពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ដែលជាថ្ងៃដែលសហជីពសម្លេងយុវជនខ្មែរ ទទួលបានបង្កាន់ដៃបញ្ជាក់ពីការស្នើសុំចុះបញ្ជិកាសហជីព មកដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ ដែលជាថ្ងៃសវនាការ គឺមានរយៈពេលលើសពីពីរខែរួចហើយ។ ដូចនេះ យោងតាមកថាខណ្ឌទី២ នៃមាត្រា ២៦៨ នៃច្បាប់ស្ដីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សហជីពសម្លេងយុវជនខ្មែរ បានក្លាយជាអង្គការវិជ្ជាជីវៈស្របច្បាប់ហើយ។

មាត្រា ២៦៨ នៃច្បាប់ស្ដីពីការងារ ចែងថា ៖ *"ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិនិងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារនេះទទួលស្គាល់ ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនោះត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាល ទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បី*

*សុំចុះបញ្ជិកា ។*

*... ការតំកល់ទុកនេះ ត្រូវធ្វើជាថ្មីម្តងទៀតនៅពេលដែលមានការផ្លាស់ប្តូរលក្ខន្តិកៈ ឬអ្នកដឹកនាំ ។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារខាងលើនេះ មានន័យថា អង្គការវិជ្ជាជីវៈទទួលបានទូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលច្បាប់ស្តីពីការងារទទួលស្គាល់ នៅពេលដែលអង្គការវិជ្ជាជីវៈ និងបញ្ជីរាយរាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ បានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

នៅក្នុងសេចក្តីបង្គាប់មុនៗក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ឃើញដែរថា សិទ្ធិ និងផលប្រយោជន៍នេះ រួមបញ្ចូលទាំងសិទ្ធិរបស់សហជីពក្នុងការតំណាងសមាជិករបស់ខ្លួន មកដោះស្រាយវិវាទ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៦-ឃ្វីកស៊ូ ហេតុផលចំណុចវិវាទទី២, លេខ ៣០/០៨-អ៊ីហ្គាមេទ,លេខ ៣១/០៨-សៅធន៍ប៊ើរ និងលេខ ៩៤/០៩-តាកហ្វាត)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗដែរ ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកអះអាងថា គាត់បានឃើញលិខិតជូនដំណឹងស្តីពីសមាសភាពថ្នាក់ដឹកនាំសហជីពសម្លេងយុវជនខ្មែរ ក្នុងអំឡុងខែតុលា ។ លើសពីនេះទៀត ភាគីទាំងពីរទទួលស្គាល់នៅក្នុងសវនាការថា ក្នុងអំឡុងពេលពីរខែនេះ ពួកគាត់មិនដែលបានទទួលលិខិតផ្លូវការណាមួយទាក់ទងនឹងការបដិសេធសមាសភាពថ្នាក់ដឹកនាំសហជីព ឬការចុះបញ្ជិកាសហជីពទេ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា យោងតាមមាត្រា ២៦៨ នៃច្បាប់ស្តីពីការងារខាងលើ កម្មការិនី ខ្វាន់ សុខលី ជាថ្នាក់ដឹកនាំសហជីពសម្លេងយុវជនខ្មែរ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើការបញ្ឈប់កម្មការិនី ខ្វាន់ សុខលី ធ្វើឡើង ស្របតាមនីតិវិធីដែរ ឬទេ?

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារបានចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួនអាចធ្វើទៅបានលុះត្រាណាតែមានការយល់ព្រមពីអធិការការងារ ។..."*

មាត្រានេះក៏ត្រូវបានអនុវត្តចំពោះថ្នាក់ដឹកនាំសហជីពផងដែរ ដូចមានចែងក្នុងកថាខ័ណ្ឌទី ២ ប្រការ ៤ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលចែងថា *"...ផុតរយៈពេលកំណត់ក្នុងកថាខណ្ឌខាងលើ ការការពារនេះត្រូវបានផ្តល់ឱ្យអ្នកដឹកនាំសហជីព ០៣ នាក់ ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៨២ និង២៩៣ នៃច្បាប់ស្តីពីការងារ ។..."*

តាមរយៈខ្លឹមសារនៃប្រការ ៤ កថាខ័ណ្ឌទី ២ នៃប្រកាសលេខ ៣០៥ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ថ្នាក់ដឹកនាំសហជីព ត្រូវទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ ដូចប្រតិភូបុគ្គលិកដែរ ពោលគឺ រាល់ការបញ្ឈប់ថ្នាក់ដឹកនាំសហជីពអាចធ្វើទៅបាន លុះត្រាណាតែមានការយល់ព្រមពីអធិការការងារ ។ នៅក្នុងករណីនេះ កម្មការិនី ខ្វាន់ សុខលី ជាថ្នាក់ដឹកនាំសហជីពសម្លេងយុវជនខ្មែរ ។ ហេតុនេះ កម្មការិនី នេះ ត្រូវទទួលបានការការពារពិសេស ពីការបញ្ឈប់ពីការងារ ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវទទួលបានការអនុញ្ញាតពីអធិការការងារជាមុន ក្នុងការបញ្ឈប់កម្មករនិយោជិតដែលទទួលបានការការពារពីការបញ្ឈប់ពីការងារ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១០៧/០៨-ស៊ីវ៉ាតិច ហេតុផលវិវាទទី២, លេខ ០៣/០៩-ស៊ីង តាយ ហេតុផលចំណុចវិវាទទី១ និង លេខ ០២/១២-តេ យុង ហេតុផលចំណុចវិវាទទី១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ និយោជកបញ្ឈប់កម្មការិនី ខ្វាន់ សុខលី ពីការងារនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤។ ភាគីនិយោជកបញ្ជាក់ថា និយោជកមិនបានទទួលការអនុញ្ញាតពីអធិការការងារមុននោះទេ មុននឹងបញ្ឈប់កម្មការិនីនេះពីការងារ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបញ្ឈប់ កម្មការិនី ខ្វាន់ សុខលី ពីការងារមិនសមស្របតាមនីតិវិធីនៃច្បាប់ស្តីពីការងារឡើយ។

ប្រការ៣៤ នៃប្រកាស ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យ ភាគីវិវាទផ្តល់នូវសំណងរដ្ឋ ឬវេណី ឬសំណងខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ក.បញ្ជាឱ្យទទួលយកកម្មករនិយោជិតដែលបានបណ្តេញចេញ ឱ្យចូលមកធ្វើការវិញ...* ។"

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកទទួលយកកម្មការិនី ខ្វាន់ សុខលី ចូលធ្វើការវិញ និងគិតរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១៖**

បង្គាប់ឱ្យនិយោជកទទួលយកកម្មការិនី ខ្វាន់ សុខលី ចូលធ្វើការវិញ និងគិតរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេខ ទូចហ៊ុន**

ហត្ថលេខា ៖ ------------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖------------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------------------